# សេចក្តីណែនាំអំពីរបៀបបំពេញក្នុងគេហទំព័រប្រកាសព័ត៌មានអតិថិជន (អតិថិជនជាឯកត្តបុគ្គល)

## 1 អំពីចំណុចខាងក្រោមដែលបង្ហាញនៅអេក្រង់បំពេញចម្លើយ សូមបំពេញព័ត៌មានអតិថិជនក្នុងពេលបច្ចុប្បន្ន។

(1)"生年月日" (ថ្ងៃខែឆ្នាំកំណើត) "国籍" (សញ្ជាតិ)ជាដើម
(2)"外国PEPs情報" (ព័ត៌មានPEPs បរទេស)
(3)"ご利用目的" (គោលបំណងប្រើប្រាស់)
(4)"ご職業" (មុខរបរ) "事業/業種" (កម្មវត្ថុអាជីវកម្ម/វិស័យ)
(5)"ご勤務先・ご就学先" (កន្លែងធ្វើការ/កន្លែងសិក្សា) (*សូមសហការឆ្លើយក្នុងកម្រិតដែលមិនបង្កផលលំបាក)
(6)"年収・年商" (ប្រាក់ចំណូលប្រចាំឆ្នាំ/ចំណូលការលក់ប្រចាំឆ្នាំ) (*សូមសហការឆ្លើយក្នុងកម្រិតដែលមិនបង្កផលលំបាក)
(7)"毎月のお取引金額(合計)" (ទំហំទឹកប្រាក់ប្រតិបត្តិការរៀងរាល់ខែ(សរុប)) "お取引の頻度" (ចំនួនដងនៃប្រតិបត្តិការ)
(8)"お取引の原資" (ប្រភពមូលធនសម្រាប់ប្រតិបត្តិការ)
(9)"200万円超の現金取引予定" (គម្រោងធ្វើប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី200ម៉ឺនយ៉េន)
(10)"国際送金の利用予定" (គម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ)
(11)"経済制裁対象国等との取引" (ប្រតិបត្តិការជាមួយប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច)

## 2 សូមពិនិត្យខ្លឹមសារដែលបំពេញនៅអេក្រង់ពិនិត្យចម្លើយ ហើយបើខ្លឹមសារដែលបំពេញគឺត្រឹមត្រូវ សូមចុចប៊ូតុង "回答" (ផ្តល់ចម្លើយ)។ បើត្រូវកែតម្រូវ សូមចុចប៊ូតុង "修正する" (កែតម្រូវ) ដើម្បីត្រឡប់ទៅអេក្រង់បំពេញចម្លើយ ហើយកែតម្រូវខ្លឹមសារដែលបំពេញ។

*បើត្រូវការចម្លងទុកខ្លឹមសារចម្លើយ សូមរក្សាទុកច្បាប់ចម្លងនៃអេក្រង់ពិនិត្យចម្លើយ ឬព្រីនជាដើមនូវអេក្រង់នៃកម្មវិធីរុករក។

## 3 បើអេក្រង់បញ្ចប់ត្រូវបានបង្ហាញ នោះការផ្តល់ចម្លើយត្រូវបានបញ្ចប់។ សូមអរគុណចំពោះការសហការ។


(អេក្រង់បំពេញចម្លើយ①)
បំពេញ (1)-(6)


(អេក្រង់បំពេញចម្លើយ②)
បំពេញ (7)-(11)


(អេក្រង់ពិនិត្យចម្លើយ)
ពិនិត្យខ្លឹមសារចម្លើយ


(អេក្រង់បញ្ចប់)
ចម្លើយត្រូវបានបញ្ចប់

# ចំណុចចង់សូមឲ្យប្រុងប្រយ័ត្នពេលបំពេញចម្លើយ

## 1 ក្រោយឡុកអ៊ីន បើកន្លងផុត 20នាទីដោយស្ថិតនៅអេក្រង់ដដែល នោះនឹងត្រូវបានឡុកអោតដោយស្វ័យប្រវត្តិដើម្បីការពារព័ត៌មាន។

ក្នុងករណីនេះ ព័ត៌មានដែលបានបំពេញរួចនឹងត្រូវបានលុបចោល ហេតុនេះសូមប្រុងប្រយ័ត្ន។
(សូមអធ្យាស្រ័យដោយសូមឡុកអ៊ីនម្តងទៀតហើយបំពេញឡើងវិញពីដំបូង)

## 2 ប៊ូតុង "ត្រឡប់" និង "ធ្វើបច្ចុប្បន្នភាព" របស់កម្មវិធីរុករក នឹងធ្វើឲ្យប្រព័ន្ធកើតមានបញ្ហាកំហុស ហេតុនេះសូមកុំប្រើប្រាស់។

ក្នុងករណីឡុកអោតដោយសារបញ្ហាកំហុសនៃប្រព័ន្ធ ព័ត៌មានដែលបំពេញរួចនឹងត្រូវបានលុបចោល។
(សូមអធ្យាស្រ័យដោយសូមឡុកអ៊ីនម្តងទៀតហើយបំពេញឡើងវិញពីដំបូង)

# 1. អំពីចំណុចខាងក្រោមដែលបង្ហាញនៅអេក្រង់បំពេញចម្លើយ សូមបំពេញព័ត៌មានអតិថិជនក្នុងពេលបច្ចុប្បន្ន។

## 1 សូមបំពេញ "生年月日" (ថ្ងៃខែឆ្នាំកំណើត) "国籍" (សញ្ជាតិ) ជាដើម។

- ចំពោះអ្នកមានសញ្ជាតិជប៉ុន អ្នកស្នាក់នៅអចិន្ត្រៃយ៍ សូមជ្រើសរើស "日本国籍　または　外国籍の特別永住者" (សញ្ជាតិជប៉ុន ឬ អ្នកស្នាក់នៅអចិន្ត្រៃយ៍ដែលមានសញ្ជាតិបរទេស)។
- ចំពោះអ្នកមានសញ្ជាតិបរទេស សូមជ្រើសរើស "外国籍 (特別永住者を除く)" (សញ្ជាតិបរទេស(លើកលែងអ្នកស្នាក់នៅអចិន្ត្រៃយ៍)) ហើយជ្រើសរើសឈ្មោះប្រទេសពីបញ្ជី។
- ចំពោះអ្នកមានប័ណ្ណស្នាក់នៅ សូមបំពេញ ❶"在留資格" (ប្រភេទទិដ្ឋាការ) ❷"在留期間 (満了日)" (រយៈពេលស្នាក់នៅ(ថ្ងៃផុតកំណត់)) ❸"在留カード番号" (លេខប័ណ្ណស្នាក់នៅ)(*)។
  * ចំពោះមន្ត្រីការទូតជាដើមដែលមិនត្រូវបានផ្តល់ជូនប័ណ្ណស្នាក់នៅ មិនចាំបាច់បំពេញលេខប័ណ្ណស្នាក់នៅឡើយ។




សូមជ្រើសរើសថ្ងៃខែឆ្នាំកំណើត។

សូមជ្រើសរើសសញ្ជាតិ។
* ចំពោះអ្នកមានសញ្ជាតិជប៉ុន អ្នកស្នាក់នៅអចិន្ត្រៃយ៍ សូមជ្រើសរើស (សញ្ជាតិជប៉ុន ឬ អ្នកស្នាក់នៅអចិន្ត្រៃយ៍ដែលមានសញ្ជាតិបរទេស)។

[សម្រាប់អ្នកមានសញ្ជាតិបរទេស]




[សម្រាប់តែអ្នកមានសញ្ជាតិបរទេស]
សូមជ្រើសរើសឈ្មោះប្រទេសពីបញ្ជី។

[សម្រាប់តែអ្នកមានសញ្ជាតិបរទេស]
សូមជ្រើសរើសប្រភេទទិដ្ឋាការពីបញ្ជី។

[សម្រាប់តែអ្នកមានសញ្ជាតិបរទេស]
សូមជ្រើសរើសរយៈពេលស្នាក់នៅ(ថ្ងៃផុតកំណត់)។ ចំពោះអ្នកមានប្រភេទទិដ្ឋាការជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ជាដើមដែលរយៈពេលស្នាក់នៅគ្មានកាលកំណត់ សូមជ្រើសរើស "無期限" (គ្មានកាលកំណត់)។

[សម្រាប់តែអ្នកមានសញ្ជាតិបរទេស]
សូមបំពេញលេខប័ណ្ណស្នាក់នៅ។
* ចំពោះមន្ត្រីការទូតជាដើមដែលមិនត្រូវបានផ្តល់ជូនប័ណ្ណស្នាក់នៅ មិនចាំបាច់បំពេញលេខប័ណ្ណស្នាក់នៅឡើយ។




[សម្រាប់តែអ្នកមានសញ្ជាតិបរទេស]
ចំពោះអ្នកមានមុខរបរដែលត្រូវបានកំណត់ជាពិសេសដូចជាមន្ត្រីការទូតជាដើម សូមជ្រើសរើសជម្រើសដែលត្រូវលក្ខខណ្ឌ។ បើមិនត្រូវលក្ខខណ្ឌ មិនចាំបាច់ជ្រើសរើសឡើយ។

[សម្រាប់តែអ្នកមានសញ្ជាតិបរទេស]
ប្រសិនបើកំពុងធ្វើការនៅការិយាល័យជាដើម (ក្រុមហ៊ុន ការិយាល័យ ហាង ការិយាល័យផ្នែកលក់ជាដើម) ដែលស្ថិតនៅប្រទេសជប៉ុន សូមជ្រើសរើស "はい" (បាទ/ចាស)។ ប្រសិនបើមិនកំពុងធ្វើការ សូមជ្រើសរើស "いいえ" (ទេ)។

## 2 សូមបំពេញ "外国PEPs情報" (ព័ត៌មានPEPs បរទេស)។

- ប្រសិនបើត្រូវលក្ខខណ្ឌជា PEPs បរទេស (អ្នកមានឋានៈក្នុងជួររាជការសំខាន់របស់រដ្ឋាភិបាលបរទេសជាដើមឬក្រុមគ្រួសារពួកគេ) សូមជ្រើសរើស "はい" (បាទ/ចាស)។ ប្រសិនបើមិនត្រូវលក្ខខណ្ឌ សូមជ្រើសរើស "いいえ" (ទេ)*។
  - * PEPs បរទេស សំដៅលើមេដឹកនាំបរទេស ព្រមទាំងអ្នកមានឋានៈសំខាន់ក្នុងរដ្ឋាភិបាល ធនាគារកណ្ដាល និងស្ថាប័នស្រដៀងគ្នានេះផ្សេងទៀត របស់បរទេស (ឬក្រុមគ្រួសារពួកគេ)។ ឧទាហរណ៍ អ្នកមានឋានៈឬមុខតំណែងជាដើមដែលមានកម្រិត (ឬក្រុមគ្រួសារពួកគេ) ប៉ុណ្ណោះដែលត្រូវលក្ខខណ្ឌ ដូចជាឯកអគ្គរាជទូត នាយកជាដើមនៃសហគ្រាសគ្រប់គ្រងដោយរដ្ឋ របស់បរទេស។ ព័ត៌មានលម្អិត សូមមើល ["外国政府等において重要な地位を占める方"について ] (អំពី "អ្នកមានឋានៈសំខាន់ក្នុងរដ្ឋាភិបាលបរទេសជាដើម")។




សូមជ្រើសរើស "はい" (បាទ/ចាស)" ឬ "いいえ" (ទេ)។

[សម្រាប់អ្នកត្រូវលក្ខខណ្ឌ PEPs បរទេស]




[សម្រាប់តែអ្នកត្រូវលក្ខខណ្ឌ PEPs បរទេស]
បើអ្នកដែលមានឋានៈសំខាន់គឺជាសាមីខ្លួនម្ចាស់គណនី សូមជ្រើសរើស "ご本人" (សាមីខ្លួន)។
ប្រសិនបើអ្នកមានឋានៈសំខាន់គឺជាក្រុមគ្រួសាររបស់ម្ចាស់គណនីសូមជ្រើសរើស"ご家族"(ក្រុមគ្រួសារ)ហើយជ្រើសរើសឈ្មោះនិង "続柄(配偶者、父母、子　等)" (ទំនាក់ទំនង (ប្ដីប្រពន្ធ ឪពុកម្ដាយ កូន ជាដើម))។

[សម្រាប់តែអ្នកត្រូវលក្ខខណ្ឌ PEPs បរទេស]
សូមជ្រើសរើសឈ្មោះប្រទេសដែលមានឋានៈសំខាន់ពីបញ្ជី។

[សម្រាប់តែអ្នកត្រូវលក្ខខណ្ឌ PEPs បរទេស]
សូមបំពេញឈ្មោះស្ថាប័នដែលមានឋានៈសំខាន់។
(ឧទាហរណ៍) ស្ថានទូត●●ប្រចាំប្រទេសជប៉ុន

[សម្រាប់តែអ្នកត្រូវលក្ខខណ្ឌ PEPs បរទេស]
សូមបំពេញឋានៈសំខាន់។
(ឧទាហរណ៍) នាយករដ្ឋមន្ត្រី
ឯកអគ្គរដ្ឋរាជទូតពេញសមត្ថភាព

## 3 សូមបំពេញ "ご利用目的" (គោលបំណងប្រើប្រាស់)។

- អំពីគោលបំណងធ្វើប្រតិបត្តិការជាមួយធនាគារប្រៃសណីយ៍ (រួមទាំងប្រៃសណីយ៍) សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។
  "主なご利用目的" (គោលបំណងប្រើប្រាស់ចម្បង)៖ សូមជ្រើសរើសចំណុច 1 ដែលត្រូវលក្ខខណ្ឌ។
  "上記以外のご利用目的"(គោលបំណងប្រើប្រាស់ក្រៅពីខាងលើ)៖បើមានគោលបំណងប្រើប្រាស់ក្រៅពីគោលបំណងប្រើប្រាស់ចម្បងខាងលើសូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។
  
  ឧទាហរណ៍) ប្រសិនបើ"主なご利用目的" (គោលបំណងប្រើប្រាស់ចម្បង)គឺជា "ទទួលប្រាក់ខែ" ប៉ុន្តែក្រៅពីនោះក៏ប្រើប្រាស់សម្រាប់ "ទូទាត់ចំណាយការរស់នៅ" ដូចជាការកាត់ស្វ័យប្រវត្តិទូទាត់ថ្លៃសេវាសាធារណ: ការទូទាត់ប័ណ្ណឥណទានជាដើម "សន្សំ" មូលធនសល់លើស នោះត្រង់"主なご利用目的" (គោលបំណងប្រើប្រាស់ចម្បង) សូមជ្រើសរើស"給与受取/年金受取" (ទទួលប្រាក់ខែ/ទទួលប្រាក់សោធននិវត្តន៍) ហើយត្រង់"上記以外のご利用目的" (គោលបំណងប្រើប្រាស់ក្រៅពីខាងលើ) សូមជ្រើសរើស"生計費決済" (ទូទាត់ចំណាយការរស់នៅ) និង"貯蓄/資産運用" (សន្សំ/គ្រប់គ្រងទ្រព្យសកម្ម)។




សូមជ្រើសរើសគោលបំណងប្រើប្រាស់ចម្បង 1 ។
ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 20តួអក្សរ)
* ប្រសិនបើលើស20តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

បើមានគោលបំណងប្រើប្រាស់លើសពីមួយ សូមជ្រើសរើសជម្រើសទាំងអស់ដែលត្រូវលក្ខខណ្ឌពីគោលបំណងប្រើប្រាស់ក្រៅពីខាងលើ។

## 4 សូមបំពេញ "ご職業" (មុខរបរ) "事業/業種" (កម្មវត្ថុអាជីវកម្ម/វិស័យ)។

- អំពី"ご職業" (មុខរបរ)ចម្បងរបស់ម្ចាស់គណនី សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។ (អាចជ្រើសរើសលើសពីមួយ)
- តាមមុខរបរដែលបានជ្រើសរើស សូមជ្រើសរើសទាំង"事業/業種" (កម្មវត្ថុអាជីវកម្ម/វិស័យ)របស់កន្លែងធ្វើការពីបញ្ជីផងដែរ។




សូមជ្រើសរើសមុខរបរដែលត្រូវលក្ខខណ្ឌ។ (អាចជ្រើសរើសលើសពីមួយ) ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 10តួអក្សរ)

* ប្រសិនបើលើស10តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

[សម្រាប់អ្នកដែលត្រូវលក្ខខណ្ឌនឹង "会社員/団体職員" (បុគ្គលិកក្រុមហ៊ុន/បុគ្គលិកអង្គការសមាគម) "会社役員/団体役員" (នាយកក្រុមហ៊ុន/នាយកអង្គការសមាគម) "パート/アルバイト/派遣社員/契約社員" (បុគ្គលិកធ្វើការតិចម៉ោង/បុគ្គលិកធ្វើការក្រៅម៉ោង/បុគ្គលិកបណ្តោះអាសន្ន/បុគ្គលិកជាប់កិច្ចសន្យា) "個人事業主/自営業" (ប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ/បើកអាជីវកម្ម)]
* ចំពោះអ្នកមានមុខរបរក្រៅពីនេះ កម្មវត្ថុអាជីវកម្ម/វិស័យនឹងមិនត្រូវបានបង្ហាញឡើយហេតុនេះមិនចាំបាច់បំពេញឡើយ។




ចំពោះអ្នកដែលមុខរបរត្រូវលក្ខខណ្ឌនឹង បុគ្គលិកក្រុមហ៊ុន/បុគ្គលិកអង្គការសមាគម នាយកក្រុមហ៊ុន/នាយកអង្គការសមាគម បុគ្គលិកធ្វើការតិចម៉ោង/បុគ្គលិកធ្វើការក្រៅម៉ោង/បុគ្គលិកបណ្តោះអាសន្ន/បុគ្គលិកជាប់កិច្ចសន្យា ប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ/បើកអាជីវកម្ម សូមជ្រើសរើសកម្មវត្ថុអាជីវកម្ម/វិស័យចម្បងពីបញ្ជី។ (រួមទាំងកម្មវត្ថុអាជីវកម្ម/វិស័យផ្សេងអាចជ្រើសរើសបានយ៉ាងច្រើនដល់ 3) ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 10តួអក្សរ)

* ប្រសិនបើលើស 10តួអក្សរ សូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

## 5 សូមបំពេញ "ご勤務先･ご就学先" (កន្លែងធ្វើការ/កន្លែងសិក្សា)។

• សូមបំពេញព័ត៌មានរបស់កន្លែងធ្វើការ កន្លែងសិក្សា <u>ក្នុងកម្រិតដែលមិនបង្កផលលំបាក</u>។




សូមបំពេញឈ្មោះ/ឈ្មោះហាងរបស់កន្លែងធ្វើការ
(ចំពោះអ្នកដែលជាសិស្សគឺ កន្លែងសិក្សា)។ (មិនលើស 30តួអក្សរ)
* ប្រសិនបើលើស30តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។
* បើមានកន្លែងធ្វើការជាដើមលើសពីមួយ សូមបំពេញអំពីកន្លែងចម្បង 1។

សូមបំពេញអាសយដ្ឋាន/លេខទូរសព្ទរបស់កន្លែងធ្វើការ
(ចំពោះអ្នកដែលជាសិស្សគឺកន្លែងសិក្សា)។
* បើមានលេខទូរសព្ទលើសពីមួយ សូមបំពេញមួយណាក៏បាន។
* លេខទូរសព្ទមិនចាំបាច់បំពេញសញ្ញាគ្រែ (-) ឡើយ។

អំពីមុខតំណែងនៅកន្លែងធ្វើការសូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។ (ករណីជាសិស្ស គឺមិនចាំបាច់)
ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 10តួអក្សរ)
* ប្រសិនបើលើស10តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

អំពីខ្លឹមសារការងារនៅកន្លែងធ្វើការសូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។ (ករណីជាសិស្ស គឺមិនចាំបាច់)
ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 10តួអក្សរ)
* ប្រសិនបើលើស10តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

## 6 សូមបំពេញ "年収･年商" (ប្រាក់ចំណូលប្រចាំឆ្នាំ/ចំណូលការលក់ប្រចាំឆ្នាំ)។

- អំពី"年収(個人事業主の方は年商)"(ប្រាក់ចំណូលប្រចាំឆ្នាំ(ចំណូលការលក់ប្រចាំឆ្នាំចំពោះអ្នកប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ))បច្ចុប្បន្នសូមបំពេញក្នុងកម្រិតដែលមិនបង្កផលលំបាក។
  * ករណីដែលម្ចាស់គណនីគ្មានចំណូលផ្ទាល់ខ្លួន សូមជ្រើសរើស "0～100万円以下" (0～100ម៉ឺនយ៉េនចុះ)។
  * ក្រៅពីប្រាក់ខែនិងប្រាក់សោធននិវត្តន៍ ក៏រួមបញ្ចូលទាំងចំណូលឈ្នួលផ្ទះជាដើមដែរ។




សូមជ្រើសរើសប្រាក់ចំណូលប្រចាំឆ្នាំ (ចំណូលការលក់ប្រចាំឆ្នាំ ចំពោះអ្នកប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ) បច្ចុប្បន្ន។

## 7 សូមបំពេញ "毎月のお取引金額(合計)" (ទំហំទឹកប្រាក់ប្រតិបត្តិការរៀងរាល់ខែ(សរុប)) "お取引の頻度" (ចំនួនដងនៃប្រតិបត្តិការ)។

- អំពីទំហំទឹកប្រាក់ប្រតិបត្តិការដែលគ្រោងធ្វើ (បញ្ញើ បង់ប្រាក់ត្រឡប់ទៅវិញ វេរប្រាក់ កាត់ស្វ័យប្រវត្តិទូទាត់ជាដើម) និងចំនួនដងនៃប្រតិបត្តិការ សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។
  * មិនគិតបញ្ចូលការដកដាក់ប្រាក់ក្នុងបរិមាណច្រើនដែលកើតឡើងបែបមួយគ្រាដូចជាការទិញរថយន្តឬទិញផ្ទះជាដើម។
  * <u>ករណីទំហំទឹកប្រាក់ ចំនួនដង គឺខុសគ្នាខ្លាំងតាមខែ សូមឆ្លើយដោយគិតជាមធ្យម។</u>

[ឧទាហរណ៍នៃ"毎月のお取引金額(合計)" (ទំហំទឹកប្រាក់ប្រតិបត្តិការរៀងរាល់ខែ(សរុប))]
ប្រសិនបើប្រាក់ខែរៀងរាល់ខែត្រូវបានដាក់ចូល 20ម៉ឺនយ៉េនហើយបង់ប្រាក់ត្រឡប់ទៅវិញ 10ម៉ឺនយ៉េនដោយសារការទូទាត់ចំណាយការរស់នៅ នោះទំហំទឹកប្រាក់ប្រតិបត្តិការនឹងទៅជា 30ម៉ឺនយ៉េន ហេតុនេះត្រូវលក្ខខណ្ឌនឹង "10万円超～ 50万円以下" (លើស10ម៉ឺនយ៉េន～50ម៉ឺនយ៉េនចុះ)។

[ឧទាហរណ៍នៃ"お取引の頻度" (ចំនួនដងនៃប្រតិបត្តិការ)]
ប្រសិនបើក្នុងរយៈ1សប្តាហ៍ដកប្រាក់នៅATM 2ដង ហើយការកាត់ស្វ័យប្រវត្តិទូទាត់មាន 1ដង នោះត្រូវលក្ខខណ្ឌនឹង "週に3回以上" (មួយសប្តាហ៍ 3ដងឡើង)។



## 8 សូមបំពេញ "お取引の原資" (ប្រភពមូលធនសម្រាប់ប្រតិបត្តិការ)។

- អំពី"原資" (ប្រភពមូលធន) ចម្បងសម្រាប់ប្រតិបត្តិការ (ប្រភពនៃមូលធនសម្រាប់ប្រតិបត្តិការ ប្រភពចម្បងនៃមូលធនដែលដាក់បញ្ចូលក្នុងគណនី) នៃគណនីធនាគារប្រៃសណីយ៍ សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។ (អាចជ្រើសរើសលើសពីមួយ)




សូមជ្រើសរើសប្រភពមូលធនសម្រាប់ប្រតិបត្តិការ។
(អាចជ្រើសរើសលើសពីមួយ)
ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 20តួអក្សរ)
* ប្រសិនបើលើស 20តួអក្សរ សូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

## 9 សូមបំពេញ "200万円超の現金取引予定" (គម្រោងធ្វើប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី200ម៉ឺនយ៉េន)។

• ករណីកំពុងប្រើប្រាស់ប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី 200ម៉ឺនយ៉េន ឬគ្រោងធ្វើនៅពេលខាងមុខ ដោយគណនីធនាគារប្រៃសណីយ៍ សូមជ្រើសរើស "はい" (បាទ/ចាស)។ ករណីមិនកំពុងប្រើប្រាស់ មិនគ្រោងធ្វើនៅពេលខាងមុខផងដែរ សូមជ្រើសរើស "いいえ" (ទេ)។

* ប្រតិបត្តិការជាសាច់ប្រាក់ជាប្រតិបត្តិការដូចជាការដាក់ប្រាក់ជាសាច់ប្រាក់ចូលគណនីការដកប្រាក់ជាសាច់ប្រាក់ពីគណនីនៅATMឬបញ្ជរការិយាល័យ។ល។ ករណីធ្វើប្រតិបត្តិការដែលដាក់ប្រាក់ជាសាច់ប្រាក់នៅATMក្នុងថ្ងៃតែមួយហើយទឹកប្រាក់សរុបនោះលើស 200ម៉ឺនយ៉េន សូមជ្រើសរើស "はい" (បាទ/ចាស)។ (មិនគិតបញ្ចូលការកាត់ស្វ័យប្រវត្តិទូទាត់ពីគណនី ការវេរប្រាក់ពីគណនីឡើយ)
* ពេលធ្វើប្រតិបត្តិការជាក់ស្តែង លោកអ្នកអាចនឹងត្រូវបានសុំឲ្យបញ្ជាក់មូលហេតុនៃប្រតិបត្តិ ប្រភពមូលធនសម្រាប់ប្រតិបត្តិការជាដើម សាជាថ្មី។




សូមជ្រើសរើស "はい" (បាទ/ចាស)" ឬ "いいえ" (ទេ)។

[សម្រាប់អ្នកដែលការមានឬគ្មានគម្រោងធ្វើប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី200ម៉ឺនយ៉េនគឺត្រូវលក្ខខណ្ឌនឹង "បាទ/ចាស"]




[សម្រាប់តែអ្នកដែលមាន គម្រោងធ្វើប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី200ម៉ឺនយ៉េន]
សូមបំពេញប្រភពនៃមូលធន គោលបំណងប្រើប្រាស់ មូលហេតុដែលត្រូវតែជាសាច់ប្រាក់ (ខ្លឹមសារជាក់លាក់នៃប្រតិបត្តិការ)។ (មិនលើស 30តួអក្សរ)

* ប្រសិនបើលើស30តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

[សម្រាប់តែអ្នកដែលមានគម្រោងធ្វើប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី200ម៉ឺនយ៉េន]
អំពីចំនួនដងនៃប្រតិបត្តិការជាសាច់ប្រាក់ដែលលើស 200ម៉ឺនយ៉េន សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។

[សម្រាប់តែអ្នកដែលមានគម្រោងធ្វើប្រតិបត្តិការជាសាច់ប្រាក់ដែលលើសពី200ម៉ឺនយ៉េន]
អំពីទំហំទឹកប្រាក់ក្នុង1ដងនៃប្រតិបត្តិការជាសាច់ប្រាក់ដែលលើស 200ម៉ឺនយ៉េន សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។

* ករណីទំហំទឹកប្រាក់ប្រតិបត្តិការគឺខុសគ្នាខ្លាំងតាមពេលធ្វើប្រតិបត្តិការ សូមឆ្លើយដោយគិតជាមធ្យម។

## 10 សូមបំពេញ "国際送金の利用予定" (គម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ)។

- ករណីកំពុងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ (ប្រតិបត្តិការវេរប្រាក់ជាមួយប្រទេសក្រៅ) ដោយគណនីធនាគារប្រៃសណីយ៍ ឬគ្រោងធ្វើនៅពេលខាងមុខ សូមជ្រើសរើស "はい" (បាទ/ចាស)។ ករណីមិនកំពុងប្រើប្រាស់ មិនគ្រោងធ្វើនៅពេលខាងមុខផងដែរ សូមជ្រើសរើស "いいえ" (ទេ)។
  * ចំពោះសេវាវេរប្រាក់អន្តរជាតិសូមឆ្លើយមិនថាជាការប្រើប្រាស់បញ្ជរការិយាល័យ ប្រើប្រាស់សេវាកម្មធនាគារប្រៃសណីយ៍ដោយផ្ទាល់ ឬទឹកប្រាក់គ្រោងធ្វើប្រតិបត្តិការមានទំហំប៉ុនណាឡើយ។
  * ពេលធ្វើប្រតិបត្តិការជាក់ស្តែង លោកអ្នកអាចនឹងត្រូវបានសុំឲ្យបញ្ជាក់គោលបំណងនៃការវេរប្រាក់ ប្រភពមូលធនសម្រាប់ប្រតិបត្តិការជាដើម សាជាថ្មី។




សូមជ្រើសរើស "はい" (បាទ/ចាស)" ឬ "いいえ" (ទេ)។

[សម្រាប់អ្នកដែល ការមានឬគ្មានគម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិគឺត្រូវលក្ខខណ្ឌនឹង បាទ/ចាស]




[សម្រាប់តែអ្នកដែលមានគម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ] អំពីគោលបំណងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ(ករណីជាអ្នកផ្ញើ ករណីជាអ្នកទទួល) សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។ (អាចជ្រើសរើសលើសពីមួយ) ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញខ្លឹមសារជាក់លាក់។ (មិនលើស 20តួអក្សរ)
* ប្រសិនបើលើស20តួអក្សរសូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

[សម្រាប់តែអ្នកដែលមានគម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ] អំពីចំនួនដងនៃការប្រើសេវាវេរប្រាក់អន្តរជាតិ សូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។

[សម្រាប់តែអ្នកដែលមានគម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ] អំពីទំហំទឹកប្រាក់ក្នុង1ដងនៃការប្រើសេវាវេរប្រាក់អន្តរជាតិសូមជ្រើសរើសចំណុចដែលត្រូវលក្ខខណ្ឌ។
* ករណីទំហំទឹកប្រាក់ប្រតិបត្តិការគឺខុសគ្នាខ្លាំងតាមពេលធ្វើប្រតិបត្តិការ សូមឆ្លើយដោយគិតជាមធ្យម។

[សម្រាប់តែអ្នកដែលមានគម្រោងប្រើប្រាស់សេវាវេរប្រាក់អន្តរជាតិ] អំពីប្រទេសជាដើមដែលជាដៃគូនៃប្រតិបត្តិការសេវាវេរប្រាក់អន្តរជាតិ សូមជ្រើសរើសឈ្មោះប្រទេសជាដើមដែលត្រូវលក្ខខណ្ឌ។ (អាចជ្រើសរើសលើសពីមួយ) ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមជ្រើសរើសឈ្មោះប្រទេសពីបញ្ជី។
* ប្រសិនបើប្រទេសជាដើមដែលជាដៃគូនៃប្រតិបត្តិការផ្សេងទៀតមានលើសពីមួយ សូមជ្រើសរើសប្រទេសជាដើមដែលជាដៃគូនៃប្រតិបត្តិការចម្បង 1។

## 11 សូមបំពេញ "経済制裁対象国等との取引" (ប្រតិបត្តិការជាមួយប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច)។

- សិនបើមានធ្វើប្រតិបត្តិការជាមួយប្រទេសជាដើមដែលត្រូវបានកំណត់ជាប្រទេស/តំបន់ដែលត្រូវបានដាក់ទណ្ឌកម្មដោយច្បាប់ស្តីពីការជួញដូររូបិយប័ណ្ណអន្តរជាតិនិងពាណិជ្ជកម្មអន្តរជាតិឬការរឹតត្បិតដោយOFACសហរដ្ឋអាមេរិចជាដើម (ប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច) ឬគ្រោងធ្វើនៅពេលខាងមុខ សូមជ្រើសរើស "はい" (បាទ/ចាស)។ ករណីមិនមានធ្វើប្រតិបត្តិការ មិនគ្រោងធ្វើនៅពេលខាងមុខផងដែរ សូមជ្រើសរើស "いいえ" (ទេ)។
  * ចំពោះប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចថ្មីបំផុត អ្នកអាចពិនិត្យបញ្ជាក់ពីគេហទំព័រធនាគារប្រៃសណីយ៍។
  * ពេលធ្វើប្រតិបត្តិការជាក់ស្តែង លោកអ្នកអាចនឹងត្រូវបានសុំឲ្យបញ្ជាក់មូលហេតុនៃប្រតិបត្តិ ប្រភពមូលធនសម្រាប់ប្រតិបត្តិការជាដើម សាជាថ្មី។




សូមជ្រើសរើស "はい" (បាទ/ចាស)" ឬ "いいえ" (ទេ)។

[សម្រាប់អ្នកដែលការមានឬគ្មានប្រតិបត្តិការជាមួយប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច គឺត្រូវលក្ខខណ្ឌនឹង បាទ/ចាស]




[សម្រាប់តែអ្នកដែលមានប្រតិបត្តិការជាមួយប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច] សូមជ្រើសរើសប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចដែលត្រូវលក្ខខណ្ឌ។ ប្រសិនបើជ្រើសរើស "その他" (ក្រៅពីនេះ) សូមបំពេញឈ្មោះប្រទេសជាដើមឲ្យជាក់លាក់។ (មិនលើស 30តួអក្សរ)
* ប្រសិនបើលើស 30តួអក្សរ សូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

[សម្រាប់តែអ្នកដែលមានប្រតិបត្តិការជាមួយប្រទេសជាដើមដែលត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ច] សូមបំពេញខ្លឹមសារជាក់លាក់នៃប្រតិបត្តិការដូចជាខ្លឹមសារនិងគោលបំណងនៃប្រតិបត្តិការ ដៃគូនៃប្រតិបត្តិការជាដើម។ (មិនលើស 40តួអក្សរ)
* ប្រសិនបើលើស 40តួអក្សរ សូមបំពេញត្រឹមកម្រិតអាចបំពេញបាន។

## 2. សូមពិនិត្យខ្លឹមសារដែលបំពេញនៅអេក្រង់ពិនិត្យចម្លើយ ហើយបើខ្លឹមសារដែលបំពេញគឺត្រឹមត្រូវ សូមចុចប៊ូតុង "回答" (ផ្តល់ចម្លើយ)។

- ខ្លឹមសារចម្លើយនឹងត្រូវបានបង្ហាញ ហេតុនេះសូមពិនិត្យខ្លឹមសារដែលបំពេញ ហើយបើខ្លឹមសារគឺត្រឹមត្រូវ សូមចុចប៊ូតុង "回答" (ផ្តល់ចម្លើយ)។
- បើត្រូវកែតម្រូវ សូមចុចប៊ូតុង "修正する" (កែតម្រូវ) នៅលើអេក្រង់ដើម្បីត្រឡប់ទៅអេក្រង់បំពេញចម្លើយ ហើយកែតម្រូវខ្លឹមសារដែលបំពេញ។
  * បើត្រឡប់ដោយប្រើប៊ូតុង "ត្រឡប់" របស់កម្មវិធីរុករក នោះខ្លឹមសារដែលបានបំពេញនឹងត្រូវបានលុបចោល ហេតុនេះសូមកុំប្រើប្រាស់។
- ក្រោយពេលចុចប៊ូតុងផ្តល់ចម្លើយរួច នឹងមិនអាចឡុកអ៊ីនម្តងទៀតបានឡើយ ហើយក៏មិនអាចមើលខ្លឹមសារចម្លើយផងដែរ។ បើត្រូវការចម្លងទុក សូមរក្សាទុកច្បាប់ចម្លងនៃអេក្រង់ពិនិត្យចម្លើយ ឬព្រីនជាដើមនូវអេក្រង់នៃកម្មវិធីរុករក។




សូមពិនិត្យខ្លឹមសារដែលបំពេញហើយ បើខ្លឹមសារដែលបំពេញគឺត្រឹមត្រូវសូមចុចប៊ូតុង "回答" (ផ្តល់ចម្លើយ)។ បើត្រូវកែតម្រូវ សូមចុចប៊ូតុង "修正する" (កែតម្រូវ) នៅលើអេក្រង់ដើម្បីត្រឡប់ទៅអេក្រង់បំពេញចម្លើយហើយកែតម្រូវខ្លឹមសារដែលបំពេញ។

* ប៊ូតុង "ត្រឡប់" របស់កម្មវិធីរុករក នឹងធ្វើឲ្យប្រព័ន្ធកើតមានបញ្ហាកំហុស ហេតុនេះសូមកុំប្រើប្រាស់។ (បើប្រព័ន្ធកើតមានបញ្ហាកំហុស នោះខ្លឹមសារដែលបានបំពេញនឹងត្រូវបានលុបចោល)

*** ក្រោយពេលចុចប៊ូតុង"回答" (ផ្តល់ចម្លើយ) រួច នឹងមិនអាចឡុកអ៊ីនម្តងទៀតបានឡើយ ហើយក៏មិនអាចមើលខ្លឹមសារចម្លើយផងដែរ។ បើត្រូវការចម្លងទុក សូមរក្សាទុកច្បាប់ចម្លងនៃអេក្រង់ពិនិត្យចម្លើយ ឬព្រីនជាដើមនូវអេក្រង់នៃកម្មវិធីរុករក។**

# 3. បើអេក្រង់បញ្ចប់ត្រូវបានបង្ហាញ នោះការផ្តល់ចម្លើយត្រូវបានបញ្ចប់។ សូមអរគុណចំពោះការសហការ។

